ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ខ្នាតសម្រាប់ការប្រឡងប្រណាំងទីក្រុងស្អាត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ៣៤.អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៧.អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធាន **គ.ជ.ទ.ស.**

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីរង្វាន់សម្រាប់ទីក្រុងដែលចូលរួមប្រឡងប្រណាំងទីក្រុងស្អាត ដើម្បីជាការលើកទឹកចិត្តនិងបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់ទីក្រុងក្នុងការរៀបចំ និងការអភិវឌ្ឍទីក្រុងរបស់ខ្លួនឱ្យស័ក្តិសមជាគោលដៅបៃតងប្រកបដោយភាពទាក់ទាញនិងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋក្នុងទីក្រុងនិងភ្ញៀវទេសចរ។

**មាត្រា ២.-**

រង្វាន់សម្រាប់ទីក្រុងជ័យលាភី ត្រូវបានផ្តល់ជូនក្រោមរូបភាពជាពានរង្វាន់ដែលមានឡាបិលរូបផ្កាវិដ្ឋូល ចាប់ពីថ្នាក់ផ្កា០១(មួយ) ផ្កា០២(ពីរ) និងផ្កា០៣(បី) ដែលមានចែងក្នុងស្តង់ដាទីក្រុងស្អាត ហើយរង្វាន់លើកទឹកចិត្តបន្ថែមទៀតក៏អាចត្រូវបានផ្តល់ជូនផងដែរ។

ពានរង្វាន់និងរង្វាន់លើកទឹកចិត្តបន្ថែមត្រូវបានប្រគល់ជូន បន្ទាប់ពីទទួលបានវិញ្ញាបនបត្រទទួលស្គាល់ដែលចេញដោយនាយករដ្ឋមន្ត្រី និងជាប្រធានកិត្តិយសនៃ **គ.ជ.ទ.ឆ.** តាមរយៈសំណើរបស់ប្រធាន **គ.ជ.ទ.ឆ.**។

រង្វាន់លើកទឹកចិត្តបន្ថែម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

វិញ្ញាបនបត្រទទួលស្គាល់និងពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣.-**

រង្វាន់លើកទឹកចិត្តសម្រាប់ទីក្រុងដែលមិនទទួលបានជ័យលាភី ត្រូវបានកំណត់ទៅតាមពិន្ទុដែលទទួលបានលើសូចនាករគោលនីមួយៗនៃស្តង់ដាទីក្រុងស្អាត។

ទីក្រុងដែលមិនទទួលបានជ័យលាភី អាចទទួលបានរង្វាន់លើកទឹកចិត្តពីប្រធាន **គ.ជ.ទ.ឆ.**។

ប្រភេទនៃរង្វាន់លើកទឹកចិត្តសម្រាប់ទីក្រុងដែលមិនទទួលបានជ័យលាភី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ទ.ឆ.**។

**មាត្រា ៤.-**

ពានរង្វាន់ត្រូវប្រគល់ជូនទីក្រុងជ័យលាភីសម្រាប់រយៈពេល០៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រទទួលស្គាល់ដោយនាយករដ្ឋមន្ត្រី។

ករណីទីក្រុងជ័យលាភីបានបាត់បង់ឬមិនគោរពតាមលក្ខណវិនិច្ឆ័យដែលមានចែងក្នុងស្តង់ដាទីក្រុងស្អាត កម្រិតនៃពានរង្វាន់អាចត្រូវបានបញ្ចុះថ្នាក់ឬដកហូតដោយនាយករដ្ឋមន្ត្រី តាមរយៈសំណើរបស់ប្រធាន **គ.ជ.ទ.ឆ.**។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធាន **គ.ជ.ទ.ឆ.** រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈ-អភិបាលរាជធានីខេត្តទាំង២៤ អគ្គលេខាធិការនៃ **គ.ជ.ទ.ឆ.** ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

*កន្លែងទទួល៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២**
**ស្តីពីការកំណត់ទ្វាន់សម្រាប់ការប្រឡងប្រណាំងទីក្រុងស្អាត**
**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**



**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**
**ដែលទទួលបានឡាបិលរូបផ្កាឈូក ១ ទង**



**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**
**ដែលទទួលបានឡាបិលរូបផ្កាឈូក ២ ទង**



**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**
**ដែលទទួលបានឡាបិលរូបផ្កាឈូក ៣ ទង**

## គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**វិញ្ញាបនបត្រទទួលស្គាល់ជ័យលាភី**

Certificate of Trophy

ផ្តល់ជូន

Awarded to

---------

(ឈ្មោះទីក្រុង)

**ទទួលបានចំណាត់ថ្នាក់ទីក្រុងស្អាត**

**ផ្ការំដួល ៣ ទង**

For Winning an Award of Clean City

3 Rumduol flowers

សុពលភាព

ថ្ងៃទី ខែ ឆ្នាំ

លេខ:........

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី**

**ដែលទទួលបានឡាបិលរូបផ្ការំដួល ៣ ទង**

## គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី




វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី
ដែលទទួលបានឡាបិលរូបផ្ការំដួល ២ ទង

## គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិញ្ញាបនបត្រទទួលស្គាល់ជ័យលាភី
Certificate of Trophy
ផ្តល់ជូន
Awarded to

\- - - - - - - -
(ឈ្មោះទីក្រុង)
ទទួលបានចំណាត់ថ្នាក់ទីក្រុងស្អាត
ផ្ការំដួល ១ ទង
For Winning an Award of Clean City
1 Rumduol flowers



សុពលភាព

ថ្ងៃទី ខែ ឆ្នាំ
លេខ:........

នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា

វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី
ដែលទទួលបានឡូហ៊ូរូបផ្ការំដួល ១ ទង